| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | សិក្សាសង្គម/ចិត្តចលភាព |
| **ប្រធានបទ** | ចម្រៀង និងតន្ត្រី |
| **ចំណងជើងមេរៀន** | រឿងម៉ូនីមេខាឡា-និងរាំ |
| **កម្រិត** | ទាប ៣០ នាទី |
| **គោលបំណង** | ការលើកតម្កើងវប្បធម៌របស់ខ្លួនតាមរយៈការច្រៀង និងរាំបែបប្រពៃណី។ |
| **បំណិនសម្បទា** | -ច្រៀងចម្រៀងនិងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀង។<br>-ទះដៃបន្ទរ ឬគោះសម្ភារៈនានាត្រូវតាមចង្វាក់នៃបទចំរៀង។ |
| **ចរិយាសម្បទា** | -ស្រឡាញ់ចូលចិត្តបទចម្រៀងច្រៀងនិងរាំយ៉ាងសប្បាយរីករាយ។ |
| **គ្រូបង្រៀន** | រៀនពីរបៀបរាំ ជ្រើសរើសបទចម្រៀងសម្រាប់ចាក់រាំ។ ធ្វើពូថៅក្រដាស និងត្បូងក្រដាសឱ្យរួចរាល់សម្រាប់ក្មេងៗទាំងអស់គ្នាម្នាក់មួយៗ។ |
| **កុមារ** | តាស្ថានភាពជាក់ស្តែងពេលលេង |
| **រៀបចំ** | -ទីកន្លែងធំល្មមទៅតាមចំនួនក្មេង។<br>-ឱ្យក្មេងៗឈរឃ្លាតឆ្ងាយពីគ្នាបន្តិចដើម្បីងាយស្រួលធ្វើកាយវិការឬរាំ កុំឱ្យប៉ះគ្នា។ |

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
| --- | --- | --- |
| 1. និយាយអំពីរឿងរបស់ឥន្ទធនូដែលត្រូវការព្រះអាទិត្យនិង ទឹកភ្លៀង។<br>2. ប្រាប់ក្មេងៗថា នេះជារឿងម៉ូនីមេខាឡា គឺជារឿងបុរាណខ្មែរ ដែលនិយាយពីស្តេចភ្លៀង និងនិយាយពីរបាំខ្មែរ។<br>3. ចាក់បទចម្រៀលីតិចៗនៅពីក្រោយ ដូចជាអ្នកអានរឿងឱ្យពួកគេស្តាប់ចឹងដែរ។<br>4. ពិភាក្សាគ្នាពីចំណុចសំខាន់ៗនៅក្នុងរឿងនេះ។ ប្រាប់ក្មេងៗពីចំណុចសំខាន់ៗទាំងនេះឬអាចនឹងបង្ហាញពីការរាំ។<br>5. ចាប់គូរឱ្យក្មេងៗដោយគូរនិមួយៗមានក្មេងប្រុសម្នាក់ និងក្មេងស្រីម្នាក់ ។<br>6. ចែកពូថៅក្រដាសឱ្យ ទៅក្មេងប្រុសៗ និងត្បូងក្រដាសឱ្យក្មេងស្រីៗ។<br>7. ប្រាប់ពួកគេថាមិនត្រូវប៉ះគ្នាទេ ប៉ុន្តែត្រូវយកពូថៅក្រដាស់វាយជាមួយត្បូងក្រដាស់ឱ្យខ្លាំងៗដើម្បីឱ្យវា | **គំរូរការរាំ**<br>1. សំពះគ្រូ<br>2. ប្រមូលទឹកសន្សើម<br>3. សំពះគ្រូម្តងទៀត និងចាប់យកក្រដាសដែលជាវត្ថុរាងៗខ្លួន<br>4. ក្មេងប្រុសសុំគ្រាប់ត្បូងពីក្មេងស្រី<br>5. ក្មេងស្រីគ្រវីក្បាលរបស់ពួកគេ<br>6. ក្មេងប្រុសព្យាយាមដេញយកត្បូងហ្នឹង<br>7. ក្មេងប្រុសគប់ពូថៅក្រដាសរបស់ខ្លួន<br>8. ក្មេងស្រី គប់ត្បូងត្រឡប់ទៅវិញ<br>9. ក្មេងប្រុសសម្តែងធ្វើជាខ្វាក់<br>10. ក្មេងស្រីរាំឆ្ងាយពីក្មេងប្រុស | 1. ស្តាប់រឿងដោយយកចិត្តទុកដាក់បំផុត។<br>2. នៅពេលដែលនិយាយគ្នាពីចំណុចសំខាន់ៗនៃរឿង សូមស្រមើល ស្រមៃថាគួរតែរាំបែបណា។<br>3. ដកយកវត្ថុដែលបានបង្កើត និងដាក់ពួកវានៅលើកម្រាល។<br>4. និយាយជាមួយដៃគូអ្នកអំពីក្បាច់រាំមួយណា ដែលត្រូវធ្វើ។<br>5. អនុវត្តការរាំដោយចងចាំថាកុំប៉ះគ្នា ហើយត្រូវចាំថាវាមិនមែនជាការប្រកួតឡើយ។<br>6. ផ្លាស់ទៅយឺតៗតាមបែបបុរាណ។<br>7. បង្ហាញការរាំរបស់អ្នកនៅក្នុងថ្នាក់ប្រសិនបើពួកគេត្រូវការ។ |

| | | |
|---|---|---|
| មានសម្លេងខ្លាំងៗ។ចាក់ប<br>ទ<br>ចម្រៀងលឺៗ និងចូរឱ្យក្មេង<br>ៗបង្កើតក្បាច់រាំតាមសាច់<br>រឿង។ នេះគឺជាគំរូរនៃការ<br>រាំ<br>ប៉ុន្តែពួកគេអាចតែងមុខមា<br>ត់ដោយខ្លួនឯងបាន។<br>8. អនុញ្ញាតប្រសិនបើក្មេងៗច<br>ង់បង្ហាញការរាំរបស់ពួកគេ<br>នៅក្នុងថ្នាក់។ | | |